រាជបណ្ឌិត្យសភាកម្ពុជា

# ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់ ជាលក្ខណៈគ្រួសារ

## ករណីសិក្សា ៖ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

## Economic Efficiency of Family Chicken Raising
Case Study: Banteay Ampil District Oddar Meanchey Province

ពឿត គួ

សារណាបរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : កសិកម្ម និង អភិវឌ្ឍន៍ជនបទ

២០២៣

រាជបណ្ឌិត្យសភាកម្ពុជា

# ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ

## ករណីសិក្សា ៖ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

## Economic Efficiency of Family Chicken Raising
## Case Study: Banteay Ampil District Oddar Meanchey Province

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ 0.0.1.2.7.0 3
រាជបណ្ឌិត្យសភាកម្ពុជា

ញឿត តួ

គ្រូណែនាំ : បណ្ឌិត ម៉ុង ស៊ាងជីម

សារណាបរិញ្ញាបត្រជាន់ខ្ពស់
ជំនាញ : កសិកម្ម និង អភិវឌ្ឍន៍ជនបទ

ឆ្នាំ ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

**លេខ** : ០៤១ / **២៣ ស.ស.រ.**

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យការពារបញ្ចប់សារណា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ១២៤ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ១១ ស.ស.រ. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្របង់ថ្លៃសិក្សាស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងគោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងចំណារឯកភាពរបស់គ្រូណែនាំចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣

## សម្រេច

**ប្រការ ១** : អនុញ្ញាតឱ្យព្រះតេជគុណ **ពឿត តូ** និស្សិត **ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៦ ខគ្គ១** ជំនាញ **កសិកម្ម និងអភិវឌ្ឍន៍ជនបទ** ការពារបញ្ចប់សារណានៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣

**ប្រការ ២** : គណៈកម្មការវាយតម្លៃសារណា មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២៣

**ប្រធាន**

បណ្ឌិតសភាចារ្យ **សុខ ទូច**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

**លេខ** : ០៤១ / **២៣ ឧ.ឧ.ន.**

# លិខិតឧទ្ទេសនាម

## គណៈកម្មការវាយតម្លៃការការពារបញ្ចប់សារណា
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ល.រ. | គោត្តនាម និង នាម | ជំនាញ | តួនាទី |
|---|---|---|---|
| ១ | បណ្ឌិត **សួន សុធឿន** | វិទ្យាសាស្ត្រ-វេជ្ជសាស្ត្រសត្វ | ប្រធាន |
| ២ | បណ្ឌិត **តាំង ស៊ិន** | វិទ្យាសាស្ត្រ-វេជ្ជសាស្ត្រសត្វ | គ្រូវាយតម្លៃទី១ |
| ៣ | បណ្ឌិត **ហ៊ីន សុខ្ខនា** | វិទ្យាសាស្ត្រ-វេជ្ជសាស្ត្រសត្វ | គ្រូវាយតម្លៃទី២ |
| ៤ | បណ្ឌិត **អ៊ិត ម៉ាណាយ** | វិទ្យាសាស្ត្រ-វេជ្ជសាស្ត្រសត្វ | គ្រូវាយតម្លៃទី៣ |
| ៥ | បណ្ឌិត **ម៉ុង ស៊ាងចឹម** | វិទ្យាសាស្ត្រ-វេជ្ជសាស្ត្រសត្វ | គ្រូណែនាំ |

- និស្សិត : **ធឿត តួ** - **ភេទ : ប្រុស**
- ជំនាញ : **កសិកម្មនិងអភិវឌ្ឍន៍ជនបទ - ជំនាន់ទី៦ ខ្ពស់១**
- ប្រធានបទ : **ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ កសិករណីសិក្សា៖ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ**
- គ្រូណែនាំ : បណ្ឌិត **ម៉ុង ស៊ាងចឹម**
- កាលបរិច្ឆេទការពារ : ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ - ម៉ោង : ៩:០០ ព្រឹក

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២៣
ប្រធាន

បណ្ឌិតសភាចារ្យ **សុខ ទូច**

**បញ្ជាក់** :
-គណៈកម្មការ និងនិស្សិត(ប្រុស) សម្លៀកបំពាក់អាវធំ
-គណៈកម្មការ និងនិស្សិត(នារី) សម្លៀកបំពាក់ប្រពៃណី ឬអាវធំ

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានបទ៖ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ**

គណៈកម្មការវាយតម្លៃសារណាបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញ កសិកម្មនិងអភិវឌ្ឍន៍ជនបទ
បញ្ជាក់ថា៖ បេក្ខជនបរិញ្ញាបត្រជាន់ខ្ពស់ **ឿត ឥទ្ធ**
ពិតជាបានការពារសារណាបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បញ្ចប់ដោយជោគជ័យ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ប្រាកដមែន។

| | |
|---|---|
| ១. បណ្ឌិត **សួន សុធឿន** | ប្រធានគណៈកម្មការ |
| ២. បណ្ឌិត **តាំង ស៊ិន** | គ្រូវាយតម្លៃទី១ |
| ៣. លោកស្រីបណ្ឌិត **ហ៊ិន សុន្ធនា** | គ្រូវាយតម្លៃទី២ |
| ៤. បណ្ឌិត **អ៊ុត ម៉ាណាយ** | សមាជិក |
| ៥. បណ្ឌិត **ម៉ុង ស៊ាងឌីម** | គ្រូណែនាំ |

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

**អគ្គលេខាធិការរង**
**ទទួលបន្ទុកមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ**

**សុត្រ សំណាង**

# មាតិកា

ទំព័រ


ឧទ្ទិសស្នាដៃ........................................I
សេចក្តីថ្លែងអំណរគុណ........................................III
អំណះអំណាង........................................V
តារាងអក្សរកាត់........................................VI
មូលន័យសង្ខេប........................................VII
មូលន័យសង្ខេបជាភាសាបរទេស (ABSTRACT)........................................IX
អារម្ភកថា........................................X


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ........................................១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ........................................២
៣. គោលបំណងនៃការស្រាវជ្រាវ........................................២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ........................................៣
៥. វិធីសាស្ត្រស្រាវជ្រាវ........................................៣
៦. សារៈប្រយោជន៍នៃការស្រាវជ្រាវ........................................៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................៥


## ជំពូក១
## រំលឹកទ្រឹស្តី


**១.១ ប្រវត្តិក្នុងវិស័យសេដ្ឋកិច្ចកសិកម្ម**........................................៧
១.១.១ លក្ខណៈធម្មជាតិនៃសេដ្ឋកិច្ចកសិកម្ម........................................១២
១.១.២ តួនាទីនៃផលិតកម្មកសិកម្ម........................................១៥
**១.២ ស្ថានភាពទូទៅនៃការចិញ្ចឹមមាន់នៅកម្ពុជា**........................................១៦
១.២.១ ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ........................................១៩
១.២.២ ការចិញ្ចឹមមាន់ជាលក្ខណៈពាក់កណ្តាលឧស្សាហកម្ម........................................២០
១.២.៣ ការចិញ្ចឹមមាន់ជាលក្ខណៈឧស្សាហកម្ម........................................២០
**១.៣ របៀបចិញ្ចឹមមាន់របស់កសិករកម្ពុជា**........................................២០
១.៣.១ ការជ្រើសរើសទីតាំងចិញ្ចឹមមាន់........................................២២
១.៣.២ ប្រភេទចំណីសំខាន់ៗសម្រាប់មាន់........................................២៧

**១.៤ ការជ្រើសរើសពូជមាន់** ............ ៣២
១.៤.១ ពូជមាន់ក្នុងស្រុក និង ពូជមាន់នាំចូល ............ ៣៤
១.៤.២ ការជ្រើសរើសមាន់សម្រាប់ធ្វើពូជ ............ ៣៩
**១.៥ កត្តាដែលមានឥទ្ធិពលលើការលូតលាស់របស់មាន់** ............ ៤២
១.៥.១ ការធ្វើអនាម័យ និង ថែទាំមាន់ ............ ៤៣
**១.៦ ជំងឺសំខាន់ៗដែលច្រើនកើតមានឡើងនៅលើសត្វមាន់** ............ ៤៦
១.៦.១ ជំងឺដែលបង្កឡើងដោយវីរុស ............ ៤៧
១.៦.២ ជំងឺដែលបង្កឡើងដោយបាក់តេរី ............ ៥០
១.៦.៣ ជំងឺដែលបង្កឡើងដោយបរាសិត ............ ៥២

## ជំពូក២

## វិធីសាស្ត្រ និង សម្ភារៈស្រាវជ្រាវ

**២.១ ទីតាំងភូមិសាស្ត្រ** ............ ៥៥
២.១.១ ទិដ្ឋភាពទូទៅក្នុងភូមិគោលដៅ ............ ៥៥
២.១.២ ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងវិស័យកសិកម្ម ............ ៥៨
**២.២ វិធីសាស្ត្រស្រាវជ្រាវ** ............ ៦០
២.២.១ វិធីសាស្ត្រ ............ ៦០
២.២.២ រូបមន្តប្រសិទ្ធភាពសេដ្ឋកិច្ចកសិកម្ម ............ ៦៣
២.២.៣ សម្ភារៈ ............ ៦៤

## ជំពូក៣

## លទ្ធផល និង ការពិភាក្សា

**៣.១ ស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់សិក្សា** ............ ៦៥
៣.១.១ ស្ថានភាពគ្រួសារ ............ ៦៥
៣.១.២ ស្ថានភាពចិញ្ចឹមសត្វនិងមុខរបរក្នុងភូមិទាំងពីរ ............ ៦៨
**៣.២ បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ** ............ ៧០
៣.២.១ ស្ថានភាពចិញ្ចឹមមាន់ក្នុងភូមិទាំងពីរ ............ ៧០
**៣.៣ ជំងឺ និង ការព្យាបាល** ............ ៧៦
៣.៣.១ វិធានការការពារ ............ ៧៩
៣.៣.២ បញ្ហាផ្សេងៗ ............ ៨១
**៣.៤ ប្រសិទ្ធភាពសេដ្ឋកិច្ច** ............ ៨៣

៣.៤.១ វិភាគសេដ្ឋកិច្ច ........................................................................................... ៩១
៣.៤.២ វិភាគប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងផលិតកម្មចិញ្ចឹមមាន់ ................................. ៩៣
៣.៤.៣ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្ម.................................................... ៩៥
**៣.៥ ការពិភាក្សា** .................................................................................................. ៩៩
៣.៥.១ ការវិភាគ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង ........... ១១១
**សន្និដ្ឋាន**
**គន្លនិទ្ទេស**
**ឧបសម្ព័ន្ធ**

# បញ្ជីទិចិត្ររូប

ល.រ លេខលំដាប់ ចំណងជើង ទំព័រ

## តារាងតួលេខ


០១ តារាងទី១ ស្ថិតិសត្វចិញ្ចឹម ឆ្នាំ២០២១-២០២២ ..... ១៧
០២ តារាងទី២ តម្រូវការប្រូតេអ៊ីនទៅតាមអាយុរបស់មាន់ ..... ២៩
០៣ តារាងទី៣ ភាគរយប្រូតេអ៊ីនដែលមានក្នុងវត្ថុធាតុស្ងួត ..... ២៩
០៤ តារាងទី៤ ប្រភពដើមរបស់បក្សី ..... ៤២
០៥ តារាងទី៥ តម្រូវការទឹករបស់មាន់ ..... ៤៣
០៦ តារាងទី៦ ប្រតិទិនចាក់ថ្នាំការពារជំងឺញូកាស់ ឬជង្គោកាច់ឱ្យមាន់ ..... ៤៨
០៧ តារាងទី៧ ការបែងចែកស្រុក និងក្រុងក្នុងខេត្តឧត្តរមានជ័យ ..... ៥៦
០៨ តារាងទី៨ ផ្ទៃដីដាំដុះ និងទិន្នផលផលក្នុងខេត្តឧត្តរមានជ័យ ..... ៥៩
០៩ តារាងទី៨ ចំនួនឈ្មោះ ភូមិ/ឃុំ/ស្រុក ដែលត្រូវចុះសិក្សាអង្កេត ..... ៦២
១០ តារាងទី១០ ស្ថានភាពអាពាហ៍ពិពាហ៍ក្នុងតំបន់សិក្សា ..... ៦៧
១១ តារាងទី១១ កម្រិតវប្បធម៌របស់អ្នកផ្តល់បទសម្ភាសន៍តាមភូមិនីមួយៗ ..... ៦៨
១២ តារាងទី១២ ចិញ្ចឹមសត្វ និងមុខរបរកសិករក្នុងភូមិគោលដៅទាំងពីរ ..... ៦៨
១៣ តារាងទី១៣ ស្ថិតិសត្វឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០២០ ..... ៦៩
១៤ តារាងទី១៤ ប្រភេទដី និងទំហំផ្ទៃដីរបស់គ្រួសារកសិករក្នុងភូមិទាំងពីរ ..... ៧០
១៥ តារាងទី១៥ ការជ្រើសរើសពូជមាន់មកចិញ្ចឹម ..... ៧២
១៦ តារាងទី១៦ ប្រភេទចំណីដែលកសិករបានផ្តល់ឱ្យមាន់ ..... ៧៤
១៧ តារាងទី១៧ តម្លៃចំណី ..... ៧៥
១៨ តារាងទី១៨ ការប្រើប្រាស់ថ្នាំសម្រាប់ព្យាបាលជំងឺមាន់ ..... ៧៩
១៩ តារាងទី១៩ ការចាក់វ៉ាក់សាំងការពារជំងឺមាន់ ..... ៨០
២០ តារាងទី២០ បញ្ហាដែលកសិករជួបប្រទះក្នុងការចិញ្ចឹមមាន់ ..... ៨២
២១ តារាងទី២១ មាន់ក្នុងគ្រួសារកសិករភូមិសឹង្ហ និង ភូមិត្រពាំងអំពិល ..... ៨៣
២២ តារាងទី២២ រយៈពេលដែលកសិករអាចលក់មាន់ និងទម្ងន់ចាប់លក់ ..... ៨៥
២៣ តារាងទី២៣ ការចំណាយលើចលនៈទុនរបស់កសិករក្នុងភូមិសឹង្ហ ..... ៨៦
២៤ តារាងទី២៤ ការចំណាយលើចលនៈទុនរបស់កសិករភូមិត្រពាំងអំពិល ..... ៨៧
២៥ តារាងទី២៥ ការចំណាយលើចលនៈទុនក្នុងមួយគ្រួសារ/ភូមិត្រពាំងអំពិល ..... ៨៩
២៦ តារាងទី២៦ ការចំណាយលើអចលនៈទុនក្នុងគ្រួសារនីមួយៗភូមិសឹង្ហ ..... ៩០
២៧ តារាងទី២៧ ចំណាយសរុប ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ/ភូមិត្រពាំងអំពិល ..... ៩០
២៨ តារាងទី២៨ ចំណាយសរុប ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ/ភូមិសឹង្ហ ..... ៩១

២៩ តារាងទី២៩ ចំណូលពីការចិញ្ចឹមមាន់នៅតំបន់សិក្សាក្នុងភូមិត្រពាំងអំពិល............៩២
៣០ តារាងទី៣០ ចំណូលពីការចិញ្ចឹមមាន់នៅតំបន់សិក្សាក្នុងភូមិសីង្ហ........................៩២
៣១ តារាងទី៣១ ចំណេញ ឬ ខាត ពីការចិញ្ចឹមមាន់នៅតំបន់សិក្សាក្នុងភូមិទាំងពីរ ....... ៩៣
៣២ តារាងទី៣២ ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម..........................................៩៤
៣៣ តារាងទី៣៣ ប្រសិទ្ធភាពថ្លៃដើមមាន់មួយក្បាល ...........................................៩៥
៣៤ តារាងទី៣៤ ប្រសិទ្ធភាពសេដ្ឋកកិច្ចនៃចលនៈទុន ...........................................៩៥
៣៥ តារាងទី៣៥ ប្រសិទ្ធភាពនៃអចលនៈទុនការចិញ្ចឹមមាន់ .....................................៩៦
៣៦ តារាងទី៣៦ ចំណុចស្រង់ដើម ............................................................... ៩៧

## ក្រាហ្វិក

០១ ក្រាហ្វិកទី១ ភេទរបស់អ្នកចូលរួមធ្វើបទសម្ភាសន៍................................................៦៥
០២ ក្រាហ្វិកទី២ អាយុរបស់ប្រជាពលរដ្ឋដែលផ្តល់បទសម្ភាសន៍....................................៦៦
០៣ ក្រាហ្វិកទី៣ ស្ថានភាពអាពាហ៍ពិពាហ៍គិតភាគរយដែលផ្តល់បទសម្ភាសន៍ ............ ៦៧
០៤ ក្រាហ្វិកទី៤ ចំនួនមាន់ដែលកសិករចិញ្ចឹមនៅក្នុងតំបន់សិក្សា ............................ ៧១
០៥ ក្រាហ្វិកទី៥ កសិករដែលបានធ្វើការព្យាបាលមាន់នៅក្នុងភូមិទាំងពីរ .................. ៧៩
០៦ ក្រាហ្វិកទី៦ ចំណាយសរុបនៅភូមិនីមួយៗក្នុងតំបន់សិក្សា.....................................៩១
០៧ ក្រាហ្វិកទី៧ ចំណូលសរុបនៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ/ភូមិទាំងពីរ ........... ៩៣
០៨ ក្រាហ្វិកទី៨ ចំណុចស្រង់ដើមរបស់កសិករចិញ្ចឹមមាន់ក្នុងភូមិត្រពាំងអំពិល............ ៩៧
៩ ក្រាហ្វិកទី៩ ចំណុចស្រង់ដើមរបស់កសិករចិញ្ចឹមមាន់ក្នុងភូមិសីង្ហ ...........................៩៨
១០ ក្រាហ្វិកទី១០ លទ្ធភាពចំណេញពីការចិញ្ចឹមមាន់ក្នុងភូមិទាំងពីរ ..........................៩៩

## ផែនទី/ទីតាំងភូមិសាស្ត្រនៃតំបន់សិក្សា

០១ ផែនទី ឃុំគោកមន
០២ ផែនទី ស្រុកបន្ទាយអំពិល

## រូបថត

០១ រូបថតទី១ សម្ភារៈដាក់ចំណីមិនសមស្រប មាន់អាចកាយ និង ធ្វើឱ្យខ្ចាយមកលើដី
០២ រូបថតទី២ សម្ភារៈដាក់ចំណីត្រឹមត្រូវ កសិករអាចការពារកុំឱ្យមាន់កាយចំណីបាន
០៣ រូបថតទី៣ ស្នូកទឹកត្រឹមត្រូវ អាចការពារកុំឱ្យមាន់លោតចូល បណ្តាលឱ្យខ្ចាយនិងកខ្វក់
០៤ រូបថតទី៤ ការដាក់មាន់គក  និងមាន់មេឱ្យមានចំនួនសមាមាត្រ
០៥ រូបថតទី៥ របៀបរៀបចំសម្បុកមាន់ក្រាបពង និងការបំបែកកូនមាន់

# មូលន័យសង្ខេប

ប្រទេសកម្ពុជា ជាប្រទេសដែលមានសក្តានុពលក្នុងវិស័យកសិកម្ម ដោយឡែកការចិញ្ចឹមសត្វ គឺជាការងារមួយដែលបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ ពិសេសការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ។ ទោះបីជាការអនុវត្តចិញ្ចឹមសត្វរបស់កសិករមិនទាន់មានលក្ខណៈបច្ចេកទេសជឿនលឿន និង មានការរាំងស្ទះខ្លះៗពីជំងឺឆ្លងក៏ដោយ ប៉ុន្តែការអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ នៅតាមទីជនបទមានការកើនឡើងជាលំដាប់ មកដល់ពេលនេះវាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្គត់ផ្គង់នូវសេដ្ឋកិច្ចគ្រួសារ និង ម្ហូបអាហារតាមតម្រូវការក្នុងស្រុកដោយមានប្រសិទ្ធភាព ក្នុងនោះការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ទទួលបាននូវការចាប់អារម្មណ៍ និង និយមចិញ្ចឹមជាងសត្វដទៃ ដោយសារតែការចិញ្ចឹមមាន់មានរយៈពេលខ្លីងាយស្រួលក្នុងការថែទាំ ផ្តល់សាច់ច្រើនហើយមានកាល់ឡូរីខ្ពស់។ល។ ហេតុនេះហើយទើបខ្ញុំលើកយកប្រធានបទស្តីពី **"ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ"** ដោយធ្វើការសិក្សាស្រាវជ្រាវនៅតំបន់គោលដៅទៅលើភូមិចំនួនពីរគឺ ភូមិត្រពាំងអំពិល និងភូមិសីង្ហ ដែលស្ថិតនៅក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

សព្វថ្ងៃនេះវិស័យកសិកម្ម ជាផ្នែកមួយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារ និងលើកកម្ពស់ប្រទេសដែលកំពុងអភិវឌ្ឍន៍ឱ្យមានការជឿនលឿន ដូចប្រទេសដទៃទៀតដែរ។ ព្រមជាមួយគ្នានេះដែរ ដោយសារមានកំណើនចំនួនប្រជាជន ដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ បានធ្វើឱ្យតម្រូវការផ្នែកស្បៀងអាហារក៏ចេះតែកើនឡើងជាលំដាប់ ដែលជាហេតុធ្វើឱ្យមានការយកចិត្តទុកដាក់ជាចម្បង ទៅលើវិស័យកសិកម្ម ជាពិសេសផ្នែកផលិតកម្មសត្វ។វិស័យកសិកម្មបានចូលរួមចំណែកក្នុងការផ្គត់ផ្គង់ស្បៀងអាហារ និងអាចកាត់បន្ថយនៅភាពក្រីក្របានមួយចំណែក សម្រាប់ប្រជាជនរស់នៅតាមទីជនបទ ដែលមានចំណូលចិត្តក្នុងការចិញ្ចឹមសត្វ គួបផ្សំជាមួយនិងមុខរបរដទៃទៀតរបស់ពួកគាត់នោះផង។

ការសិក្សានេះ ក្នុងគោលបំណងស្វែងយល់អំពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសាររបស់កសិករក្នុងតំបន់សិក្សា ក្នុងនោះមានដូចជា ធ្វើការវិភាគពីស្ថានភាពបច្ចុប្បន្ន អំពីការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ វាយតម្លៃទៅលើស្ថានភាពបច្ចុប្បន្ននៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ផ្តល់គំនិតកែលម្អបែបបច្ចេកទេសដល់កសិករក្នុងតំបន់ ផ្តល់នូវយោបល់ស្ថាបនាបន្ថែមជុំវិញ ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ដោយប្រើប្រាស់ធនធានធម្មជាតិដែលមានក្នុងតំបន់ តាមលទ្ធភាពរបស់កសិករ និងជួយប្រជាកសិករឱ្យចេះធ្វើការវិភាគសេដ្ឋកិច្ចក្នុងការរកប្រាក់ចំណូលគ្រួសារតាមរយៈការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ។

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវរួចមកឃើញថា ប្រជាជននៅក្នុងភូមិទាំងពីរច្រើនប្រកបរបរធ្វើស្រែ ចម្ការ ចិញ្ចឹមសត្វក្នុងនោះមានប្រជាកសិករចំនួន ៥គ្រួសារ ស្មើនឹង ២.១៩ ភាគរយ ដែលមានមុខរបរបន្ទាប់បន្សំជាច្រើន នៃចំនួនប្រជាជនដែលយកសំណាកសរុប

២២៨ ចំពោះការចិញ្ចឹមមាន់របស់កសិករដែលស្ថិតនៅក្នុងភូមិទាំងពីរ ពេលចាប់ផ្តើមចិញ្ចឹមមាន់គឺ តែងតែសុំពីបងប្អូន ឬ ទិញពីក្នុងភូមិ និងទិញពីផ្សារដោយមិនបានធ្វើការជ្រើសរើសពូជអ្វីទេ ពីព្រោះដោយគិតថាគ្រាន់តែចិញ្ចឹមជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ។ របៀបជ្រើសរើសពូជមាន់មកចិញ្ចឹមគឺ បានផ្តោតទៅលើតែមាន់ដែលមានមាឌធំល្អ រូបរាងស្អាត ខ្ពស់គ្រោង រោមច្រើន ពូជពងច្រើន សាយកូន យកមកចិញ្ចឹម ចំពោះការផ្តល់ចំណីគឺពឹងផ្អែកទាំងស្រុងទៅលើធនធានចំណីដែលមាននៅក្នុងភូមិដូចជា ស្រូវ អង្ករ កន្ទក់ ចុងអង្ករ និងប្រភពចំណីក្បែរៗផ្ទះតាមវាលស្រែ នៅក្នុងនោះដែរបច្ចេកទេសចិញ្ចឹមមាន់កសិករទាំងពីរភូមិ ពួកគាត់ចិញ្ចឹមមាន់មិនមានបច្ចេកទេសត្រឹមត្រូវ ដោយគ្រាន់តែចិញ្ចឹមតាមធម្មជាតិឱ្យមាន់ដើររកស៊ី ដោយខ្លួនឯងហើយផ្តល់ចំណីបន្ថែមតិចតួចប៉ុណ្ណោះ។

នៅក្នុងចំណោមកសិករដែលចូលរួមផ្តល់បទសម្ភាសន៍សរុប ២២៨ គ្រួសារ មានប្រជាកសិករ ២១៣គ្រួសារ ស្មើនឹង ៩៣ ភាគរយ ជាទូទៅពួកគាត់ចិញ្ចឹមមាន់តាមទម្លាប់ពីឪពុកម្តាយ និងពាក់កណ្តាលព្រលែង ការចិញ្ចឹមនេះមិនមានភាពខុសប្លែកពីគ្នាប៉ុន្មាននោះទេ នៅក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ រវាងកសិករទាំងពីរភូមិ ពួកគាត់ចូលចិត្តចិញ្ចឹមមាន់ និងជ្រូកជាងសត្វដទៃ។ មានប្រជាកសិករ ១៥គ្រួសារ ស្មើនឹង ៦.៥៥ ភាគរយដែលមាននៅក្នុងសំណាក បានធ្វើការសាងសង់ទ្រុងត្រឹមត្រូវសម្រាប់មាន់ដេកនៅពេលយប់ និងគ្រប់គ្រងមាន់របស់ពួកគាត់ ដែលមានសំណាញ់ការពារនូវសត្វចង្រៃផ្សេងៗ ដូចជាកណ្តុរ ឬពស់ ដើម្បីកុំឱ្យចូលស៊ីកូនមាន់របស់គាត់។ រីឯការជ្រើសរើសពូជមាន់វិញ កសិករភាគច្រើនមិនសូវមានការយល់ដឹងប៉ុន្មានទេ ជាក់ស្តែងក្នុងចំណោមកសិករ ដែលបានចូលរួមផ្តល់បទសម្ភាសន៍សរុបចំនួន ៩៣ ភាគរយ មានការចិញ្ចឹមមាន់ពូជក្នុងស្រុកចម្រុះគ្នា ដូចជាពូជមាន់ចៃ មាន់ស្លួយ និងមាន់ក្រញាស់ជាដើម។ ចំពោះការធ្វើវ៉ាក់សាំងមាន់កសិករភាគច្រើនពួកគាត់មិនបានយល់ដឹងបច្ចេកទេសទេ ដែលជាហេតុធ្វើឱ្យមាន់ងាយទទួលជំងឺ ចំណែកឯលទ្ធផលនៃការវិភាគសេដ្ឋកិច្ចវិញឃើញថា ការចិញ្ចឹមមាន់របស់កសិករទាំងពីរភូមិ បានទទួលប្រាក់ចំណេញតិចតួច ណាមួយពួកគាត់ពុំបានកត់ត្រាច្បាស់លាស់ពីការចំណាយផ្សេងៗដូចជា ថ្លៃទិញចំណី ថ្លៃទិញថ្នាំ និងថ្លៃព្យាបាលសត្វនោះទេ។ ប្រៀបធៀបពីស្ថានភាពសេដ្ឋកិច្ចក្នុងការចិញ្ចឹមមាន់របស់កសិករទាំងពីរភូមិជាទូទៅការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារគឺ មិនសូវធ្វើការចំណាយច្រើននោះទេ ម្យ៉ាងទៀតមាន់ធំជាត់យឺត តម្លៃទីផ្សារមិនសូវមានស្ថេរភាព ប៉ុន្តែពួកគាត់ចេះកែច្នៃវត្ថុធាតុដើមដែលមានស្រាប់នៅក្នុងស្រុកភូមិ។